ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
អគ្គលេខាធិការដ្ឋាន

# បទបង្ហាញ
# ស្តីពី
# ការគ្រប់គ្រងប្រតិបត្តិការកាស៊ីណូ និងការគ្រប់គ្រងផលប៉ះពាល់ពីល្បែង

រៀបចំដោយ៖ អគ្គលេខាធិការដ្ឋាននៃ គ.ល.ក.

# មាតិកា

I. ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

II. ការគ្រប់គ្រងអាជ្ញាបណ្ណ

III. ការគ្រប់គ្រងបញ្ជីគណនេយ្យនិងហិរញ្ញវត្ថុ

IV. ការគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់ និងផលប៉ះ-ពាល់ពីល្បែង

V. ទោសទណ្ឌ

# I. ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ក្នុងការគ្រប់គ្រងប្រតិបត្តិការអាជីវកម្មកាស៊ីណូ មានច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដូចខាងក្រោម៖

- ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០
- ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០
- ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០
- ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៨ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦
- អនុក្រឹត្យលេខ ១៦៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
- អនុក្រឹត្យលេខ ១៦៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ដើមទុនអប្បបរមាសម្រាប់ប្រតិបត្តិ-ការល្បែងកាស៊ីណូ

# I. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

- អនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- ប្រកាសលេខ ០០៣ គ.ល.ក.ប្រក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា និងអង្គភាពសវនកម្មផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
- ប្រកាសលេខ ០០២ គ.ល.ក.ប្រក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់ ការផ្ទេរ និងការបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូ និងអាជ្ញាបណ្ណល្បែងផ្សងសំណាង
- ប្រកាសលេខ ៦២៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការបំពេញចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ និងល្បែងផ្សងសំណាង
- ប្រកាសលេខ ០០៩ គ.ល.ក.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រងលើវិធានល្បែង ឧបករណ៍ និង/ឬកម្មវិធីល្បែងសម្រាប់ប្រតិបត្តិការកាស៊ីណូ
- ប្រកាសលេខ ០០១ គ.ល.ក.ប្រក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ស្តីពីបែបបទ នីតិវិធី និងលក្ខខណ្ឌនៃការស្នើសុំអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍

## I. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

- ប្រកាសលេខ ០០៥ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាលនិងពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- ប្រកាសលេខ ០០៦ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ
- សេចក្តីណែនាំអន្តរក្រសួងលេខ ០២៨ សណន និងលេខ ០១២ សហវ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការអនុវត្តវិធានការបង្ក្រាបល្បែងស៊ីសងខុសច្បាប់
- សេចក្តីណែនាំលេខ ០០២ គ.ល.ក. សណន ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ ស្តីពីការពង្រឹងយន្តការទប់ស្កាត់និងបង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ (Online Scam) តាមគ្រប់ប្រភេទ និងគ្រប់រូបភាពក្នុងទីតាំងកាស៊ីណូ
- សេចក្តីណែនាំលេខ ០០៥/២១ អ.គ.ល.ក. សណន ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការបំពេញចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ និងល្បែងផ្សងសំណាង
- សេចក្តីណែនាំលេខ ០០១/២២ អ.គ.ល.ក. សណន ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ ស្តីពីការបើកដំណើរការឬមិនទាន់បើកដំណើរការអាជីវកម្មរបស់ប្រតិបត្តិករកាស៊ីណូ និងល្បែងផ្សងសំណាង

# I. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

- សេចក្តីណែនាំលេខ ០០៣/២២ អ.គ.ល.ក. សណន ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការប្រើប្រាស់នាមករណ៍លើស្លាកសញ្ញា (ឃីហោ) សម្រាប់តាំងបង្ហាញរបស់ប្រតិបត្តិករកាស៊ីណូ និងល្បែងផ្សងសំណាង
- សេចក្តីណែនាំលេខ ០១១/២២ អ.គ.ល.ក. សណន ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ ស្តីពីការចុះបញ្ជីប្រភេទល្បែង វិធានល្បែង ឧបករណ៍និង/ឬកម្មវិធីល្បែងកាស៊ីណូ និងល្បែងផ្សងសំណាង
- សេចក្តីណែនាំលេខ ០១៦/២២ អ.គ.ល.ក. សណន ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសមាសភាពក្នុងកាស៊ីណូ
- សេចក្តីណែនាំលេខ ០១៨/២២ អ.គ.ល.ក. សណន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ ស្តីពីការគ្រប់គ្រងប្រតិបត្តិការកាស៊ីណូនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សេចក្តីណែនាំលេខ ០២០/២២ អ.គ.ល.ក. សណន ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២ ស្តីពីនីតិវិធីនៃការដកប្រាក់តម្កល់ធានាអាជីវកម្មរបស់ប្រតិបត្តិករកាស៊ីណូ និង/ឬប្រតិបត្តិករល្បែងផ្សងសំណាង

# I. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

- សេចក្ដីណែនាំលេខ ០០៤/២៣ អ.គ.ល.ក. សណាន ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ស្ដីពីការបំពេញចំណូលកាតព្វកិច្ចបង់កម្រៃចុះបញ្ជីប្រភេទល្បែង វិធានល្បែង ឧបករណ៍និង/ឬកម្មវិធីល្បែងសម្រាប់កាស៊ីណូ និងល្បែងផ្សងសំណាង
- សេចក្ដីណែនាំលេខ ០០៥/២៣ អ.គ.ល.ក. សណាន ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ ស្ដីពីការស្នើសុំអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ
- សេចក្ដីណែនាំលេខ ០០៨/២៣ អ.គ.ល.ក. សណាន ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ ស្ដីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ
- សេចក្ដីណែនាំលេខ ០១៣/២៣ អ.គ.ល.ក.សណាន ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ស្ដីពីការរឹតត្បិតការលេងល្បែងក្នុងកាស៊ីណូ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សេចក្ដីណែនាំលេខ ០១៥/២៣ អ.គ.ល.ក. សណាន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការស្នើសុំនាំចូលប្រភេទល្បែង វិធានល្បែង ឧបករណ៍ និង/ឬកម្មវិធីល្បែង

# II. ការគ្រប់គ្រងអាជ្ញាបណ្ណ

- **គ.ល.ក.** គ្រប់គ្រងនិងចេញអាជ្ញាបណ្ណ តាមប្រភេទនៃល្បែងពាណិជ្ជកម្មនិងសកម្មភាពពាក់ព័ន្ធ៖ *(មាត្រា៣៥)*

| ល្បែងពាណិជ្ជកម្ម | | | | សកម្មភាពពាក់ព័ន្ធ | | |
|---|---|---|---|---|---|---|
| អាជ្ញាបណ្ណកាស៊ីណូ | អាជ្ញាបណ្ណល្បែងភ្នាល់ | អាជ្ញាបណ្ណល្បែងផ្សងសំណាង | អាជ្ញាបណ្ណល្បែងពាណិជ្ជកម្មដទៃទៀត | អាជ្ញាបណ្ណបុគ្គលិកពិសេស | អាជ្ញាបណ្ណអ្នកជំរុញល្បែងពាណិជ្ជកម្ម | អាជ្ញាបណ្ណអ្នកផលិត អ្នកដំឡើង អ្នកនាំចូល អ្នកលក់ និង/ឬអ្នកចែកចាយឧបករណ៍ និង/ឬកម្មវិធីល្បែង |

- តំបន់ល្បែងពាណិជ្ជកម្ម៖ ***(មាត្រា១៨ ដល់២០)***
  - **តំបន់ហាមឃាត់៖** <u>ទីតាំងភូមិសាស្ត្រដែលត្រូវហាមឃាត់ចំពោះល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ ឬចំពោះល្បែងពាណិជ្ជកម្មមួយចំនួនដោយមូលហេតុអភិរក្ស វប្បធម៌ សាសនា ឬដោយសេចក្តីត្រូវការចាំបាច់ ឬមូលហេតុផ្សេងទៀត។</u>
  - **តំបន់អនុញ្ញាត៖** ទីតាំងភូមិសាស្ត្រទាំងឡាយណាក្រៅពីតំបន់ហាមឃាត់។
- គ្មានបុគ្គលណាអាចធ្វើប្រតិបត្តិការល្បែងពាណិជ្ជកម្មបាន លុះត្រាតែមានអាជ្ញាបណ្ណជាមុនពី **គ.ល.ក.**។
- ល្បែងពាណិជ្ជកម្មគ្រប់ប្រភេទដែលដាក់ឱ្យដំណើរការដោយប្រតិបត្តិករល្បែងពាណិជ្ជកម្ម ត្រូវមានការអនុញ្ញាតជាមុនពី **គ.ល.ក.**។

# II.ការគ្រប់គ្រងអាជ្ញាបណ្ណ

## លក្ខខណ្ឌនៃការធ្វើអាជីវកម្មកាស៊ីណូ

១ មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ (IR)

២ កាស៊ីណូ៖ កាស៊ីណូក្នុង IR និងកាស៊ីណូក្រៅ IR

៣ បុគ្គលិកពិសេសកាស៊ីណូ

៤ ការចុះបញ្ជីប្រភេទ វិធាន ឧបករណ៍និង/ឬកម្មវិធីល្បែង

៥ ការនាំចូលឧបករណ៍ និង/ឬកម្មវិធីល្បែង

# ៩. មណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍

- ប្រាក់កក់ធានាកាតព្វកិច្ច ៥% នៃដើមទុន

ធនធានហិរញ្ញវត្ថុអប្បបរមា ២ ទ្រីលានរៀល ( 500 លាន$ )

IR

ស្ថិតក្រោមកិច្ចព្រមព្រៀងអភិវឌ្ឍន៍

គុណវុឌ្ឍិបុគ្គលដាក់ពាក្យស្នើសុំ

- នីតិបុគ្គលចុះបញ្ជីពាណិជ្ជកម្ម និងពន្ធដារស្របច្បាប់កម្ពុជា
- មានគោលការណ៍អភិវឌ្ឍន៍ពីនាយករដ្ឋមន្ត្រី
- មានសិទ្ធិកម្មសិទ្ធិ ឬសិទ្ធិស្របច្បាប់នៅទីតាំងអភិវឌ្ឍន៍

**លក្ខខណ្ឌអប្បបរមានៃកិច្ចព្រមព្រៀង**

- ចំនួនទឹកប្រាក់និងដំណាក់កាលនៃការអភិវឌ្ឍ, ប្រាក់កក់ធានាកាតព្វកិច្ចជាកម្មសិទ្ធិករ IR
- គម្រោងស្ថាបត្យកម្មនិងកាលវិភាគនៃការសាងសង់
- ដំហាននៃការអភិវឌ្ឍនិង/ឬការសាងសង់ដែលត្រូវសម្រេច និងកាលបរិច្ឆេទបញ្ចប់គម្រោង
- ទំហំទីតាំងគិតជាភាគរយនៃទំហំផ្ទៃសរុបរបស់កាស៊ីណូដែលនឹងត្រូវប្រើជាទីតាំងល្បែង ទីតាំងបដិសណ្ឋារកិច្ច សណ្ឋាគារ និងភោជនីយដ្ឋាន ចំនួនជាន់និងទំហំផ្ទៃសរុបនៃកាស៊ីណូ
- ចំនួនសណ្ឋាគារ ចំណាត់ថ្នាក់សណ្ឋាគារ និងចំនួនបន្ទប់អប្បបរមានៃសណ្ឋាគារនីមួយៗ
- ចំនួនជាន់និងទំហំផ្ទៃសរុបនៃកាស៊ីណូ
- មណ្ឌលកម្សាន្តនិងមណ្ឌលទាក់ទាញផ្សេងៗរបស់ IR
- កាតព្វកិច្ចអភិវឌ្ឍផ្សេងទៀតក្រៅពីល្បែងពាណិជ្ជកម្ម
- កាតព្វកិច្ចក្នុងការថែរក្សានិងការធានារ៉ាប់រងការពារហានិភ័យសាធារណៈ។
- លក្ខខណ្ឌដែលនាំឱ្យមានការកែប្រែ ឬការបញ្ចប់កិច្ចសន្យាដោយរាជរដ្ឋាភិបាល និងករណីដែលអនុញ្ញាតឱ្យ **គ.ល.ក.** អាចដាក់ពិន័យដោយផ្អែកលើកិច្ចព្រមព្រៀង
- កាតព្វកិច្ចរបស់កម្មសិទ្ធិករ IR ក្នុងការអភិវឌ្ឍន៍តំបន់អនុញ្ញាតនូវមណ្ឌលកម្សាន្តនិងមណ្ឌលទាក់ទាញក្រៅពីល្បែងពាណិជ្ជកម្ម

***ប្រកាសលេខ ០០១ គ.ល.ក.ប្រ.ក. ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ស្តីពី បែបបទ នីតិវិធី និងលក្ខខណ្ឌ នៃការស្នើសុំអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍***

# ២. កាស៊ីណូ

## ក. ការស្នើសុំអាជ្ញាបណ្ណ

- ប្រាក់តម្កល់ ៥%
- មូលធនសុទ្ធ ១០%

**កាស៊ីណូ**

ដើមទុន៖
-៨០០ ប៊ីលានរៀល ក្នុង IR
-៤០០ ប៊ីលានរៀល ក្រៅ IR

ឯកសារតម្រូវ

គុណវុឌ្ឍិបុគ្គលដាក់ពាក្យស្នើសុំ

- នីតិបុគ្គលចុះបញ្ជីពាណិជ្ជកម្ម និងពន្ធដារស្របច្បាប់កម្ពុជា
- កម្មសិទ្ធិករ IR បុគ្គលបានចុះកិច្ចព្រមព្រៀមជាមួយកម្មសិទ្ធិករ IR
- កម្មសិទ្ធិករ ឬបុគ្គលបានចុះកិច្ចព្រមព្រៀងជាមួយប្រតិបត្តិករកាស៊ីណូ
- មានគោលការណ៍អភិវឌ្ឍន៍ពីនាយករដ្ឋមន្ត្រី

- វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន លក្ខន្តិកៈ និងប័ណ្ណពន្ធប៉ាតង់
- កំណត់ហេតុប្រជុំភាគហ៊ុនិក ស្ថាបនិក ឬក្រុមប្រឹក្សាភិបាល និងសេចក្តីសម្រេចក្រុមប្រឹក្សាភិបាលតែងតាំងនាយកប្រតិបត្តិ
- បញ្ជីរាយនាមភាគហ៊ុនិក អភិបាល ភ្ជាប់មកជាមួយអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន និងលិខិតថ្កោលទោស
- គោលការណ៍អភិវឌ្ឍ IR, Non IR ពីនាយករដ្ឋមន្ត្រី, កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ
- កិច្ចសន្យាជួលទីតាំង ឬប័ណ្ណកម្មសិទ្ធិ មានបញ្ជាក់ពីសារការី
- ប្លង់បរិវេណកាស៊ីណូ និងទីតាំងរៀបចំឧបករណ៍ល្បែង និងបញ្ជីរាយនាមឧបករណ៍និង/ឬកម្មវិធីល្បែង
- ឯកសារស្តីពីវិធានល្បែង របៀបលេង និងនីតិវិធីទូទាត់សំណង
- ឯកសារបញ្ជាក់ពីដើមទុន និងឯកសារបញ្ជាក់ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ធានានិរន្តរភាពហិរញ្ញវត្ថុ
- ឯកសារបញ្ជាក់អំពីប្រាក់តម្កល់ធានាអាជីវកម្ម
- ផែនការស្តីពីការគ្រប់គ្រងធនធានមនុស្ស និងគោលនយោបាយបណ្តុះបណ្តាលធនធានមនុស្ស
- ឯកសារស្តីពីការសិក្សាសមិទ្ធិលទ្ធភាព និងផែនការអាជីវកម្មសម្រាប់រយៈពេល ៣ ឆ្នាំខាងមុខ
- គោលការណ៍អភិបាលកិច្ចក្រុមហ៊ុន រួមមាន ការត្រួតពិនិត្យផ្ទៃក្នុង គណនេយ្យ សវនកម្ម និងប្រព័ន្ធគ្រប់គ្រងហានិភ័យ
- គោលការណ៍ប្រតិបត្តិស្តង់ដារនៃផ្នែកនីមួយៗរបស់ក្រុមហ៊ុន នីតិវិធីទប់ស្កាត់បុគ្គលហាមឃាត់
- គោលការណ៍ត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- រចនាសម្ព័ន្ធក្រុមហ៊ុនមេ (បើមាន) និងរបាយការណ៍ហិរញ្ញវត្ថុក្នុងរយៈពេល ៣ ឆ្នាំកន្លងមក (សម្រាប់សម្ព័ន្ធក្រុមហ៊ុន)។

# ២. កាស៊ីណូ ( ត )

## ខ. ការពិនិត្យនិងអនុម័ត

ពិនិត្យនិងវាយតម្លៃដោយ អ.គ.ល.ក. → ប្រជុំអនុម័ត ដោយ គ.ល.ក.

## គ. សុពលភាពអាជ្ញាបណ្ណ

សុពលភាពអាជ្ញាបណ្ណកាស៊ីណូត្រូវផ្តល់ឱ្យសម្រាប់រយៈពេលកំណត់ក្នុងអាជ្ញាបណ្ណ គិតចាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយអាជ្ញាបណ្ណជាសាធារណៈ

- មិនលើសពី **២០ ឆ្នាំ** សម្រាប់អាជ្ញាបណ្ណកាស៊ីណូស្ថិតក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ( IR )
- មិនលើសពី **៥ ឆ្នាំ** សម្រាប់អាជ្ញាបណ្ណកាស៊ីណូមិនស្ថិតក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ( Non-IR )

❑ ប្រតិបត្តិករកាស៊ីណូត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមកអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** ក្នុងរយៈពេលយ៉ាងតិច ៦ ខែ មុនពេលផុតសុពលភាពអាជ្ញាបណ្ណនោះ

# ២. កាស៊ីណូ (ត)

## ឃ. កាតព្វកិច្ចរបស់ប្រតិបត្តិករកាស៊ីណូ

- ត្រូវប្រើប្រាស់នាមករណ៍ ស្របតាមនាមករណ៍ដែលបានចុះបញ្ជី ឬមានកំណត់ក្នុងអាជ្ញាបណ្ណ *(ប្រើភាសាខ្មែរ ជំដាងភាសាបរទេស ហាមបកប្រែន័យពីភាសាមួយទៅភាសាមួយ នាមករណ៍ជាភាសាខ្មែរត្រូវមានសំនៀងដូចភាសាដទៃ)*
- ត្រូវធ្វើប្រតិបត្តិការតែនៅទីតាំងដែលមានកំណត់ក្នុងអាជ្ញាបណ្ណ
- ត្រូវតាំងបង្ហាញអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតផ្សេងៗច្បាប់ដើម នៅទីកន្លែងដែលអាចមើលឃើញក្នុងទីតាំងអាជីវកម្ម
- ត្រូវបើកដំណើរការ២៤ម៉ោងក្នុង១ថ្ងៃ រៀងរាល់ថ្ងៃពេញ១ឆ្នាំ
- ត្រូវដាក់តាំងបម្រាម ឬផ្លាកសញ្ញាហាមឃាត់ផ្សេងៗនៅមុខកាស៊ីណូ
- មិនត្រូវលួចលាក់បង្កប់ល្បែងអនឡាញខុសច្បាប់
- ត្រូវដំណើរការប្រភេទល្បែង វិធានល្បែង ឧបករណ៍ និង/ឬកម្មវិធីល្បែង ដែលបានទទួលការអនុញ្ញាតពី **គ.ល.ក.**
- ត្រូវដំណើរការល្បែង ដោយបុគ្គលិកដែលមានអាជ្ញាបណ្ណបុគ្គលិកពិសេស ទៅតាមប្រភេទដែលច្បាប់បានកំណត់
- ករណីមិនធ្វើប្រតិបត្តិការដោយផ្ទាល់៖ ត្រូវមានកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូជាមួយកម្មសិទ្ធិករកាស៊ីណូ/កម្មសិទ្ធិករ IR ដែលទទួលបានការឯកភាពពី **គ.ល.ក.** និងត្រូវផ្តល់កិច្ចសន្យា ឬកិច្ចព្រមព្រៀងនោះមក **គ.ល.ក.**
- ត្រូវរក្សាគុណវុឌ្ឍិរបស់ខ្លួនជាអ្នកកាន់កាប់អាជ្ញាបណ្ណ ក្នុងអំឡុងពេលដែលអាជ្ញាបណ្ណមានសុពលភាព (ម.៣៥)
- ត្រូវបំពេញកាតព្វកិច្ចត្រួតពិនិត្យផ្ទៃក្នុង៖ AML/CFT អំពើពុករលួយ កាតព្វកិច្ចគណនេយ្យនិងសវនកម្ម
- ត្រូវបំពេញចំណូលកាតព្វកិច្ចពីល្បែងតាមការកំណត់

# ២. កាស៊ីណូ (ត)

- **ត្រូវស្នើសុំការអនុញ្ញាតនិងយល់ព្រមជាមុនពី គ.ល.ក. ករណី៖**
  - កែប្រែលក្ខន្តិកៈ ផ្ទេរភាគហ៊ុន ផ្ទេរ ឬផ្ដល់សិទ្ធិចាត់ចែង ឬគ្រប់គ្រងកាស៊ីណូមួយផ្នែក ឬទាំងស្រុង
  - កែប្រែ ផ្លាស់ប្ដូរ ឬបំពេញបន្ថែមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូ
  - ការផ្អាក ឬបិទដំណើរការជាបណ្ដោះអាសន្ន
  - ផលិត ដំឡើង នាំចូល ចែកចាយ កម្ទេចចោលនូវឧបករណ៍/កម្មវិធីល្បែង
  - ដំណើរការសាកល្បង ឬធ្វើតេស្តឧបករណ៍/កម្មវិធីល្បែង
- **កាតព្វកិច្ចរាយការណ៍៖** កថា.១ ម.៣៣, កថា.២ ម.៣៤, កថា.៣ ម.៣៦, កថា.២ ម.៣៨, កថា.៣និង៤ ម.៤៤ កថា.២ ម.៥៨, កថា.១ ម.៦៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- ត្រូវមានសញ្ញាសម្គាល់របស់កាស៊ីណូលើកាក់ល្បែងរបស់ខ្លួន និងតាមលក្ខណបច្ចេកទេសដែលកំណត់ដោយ **គ.ល.ក.**
- ត្រូវទូទាត់ប្រាក់ឈ្នះតាមគ្រប់មធ្យោបាយឱ្យភ្ញៀវល្បែងឱ្យបានត្រឹមត្រូវគ្រប់ចំនួន
- ត្រូវហាមឃាត់ និងរាយការណ៍មក **គ.ល.ក.** ពីសកម្មភាពភ្នាល់ដោយផ្ទាល់រវាងភ្ញៀវល្បែងនិងភ្ញៀវល្បែង ក្នុងកាស៊ីណូ ឬគ្រឹះស្ថានល្បែងរបស់ខ្លួន
- មិនត្រូវដំឡើងម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) នៅក្នុងបរិវេណកាស៊ីណូ
- មិនត្រូវផ្សព្វផ្សាយពាណិជ្ជកម្មអំពីល្បែងពាណិជ្ជកម្ម ដោយគ្មានការអនុញ្ញាតជាមុនពី **គ.ល.ក.**
- អនុវត្តតាមលក្ខខណ្ឌអាជ្ញាបណ្ណ សៀវភៅបន្ទុក ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

# ៣. បុគ្គលិកពិសេសកាស៊ីណូ

## ក. ប្រភេទអាជ្ញាបណ្ណ

- ប្រភេទ កៈ សម្រាប់កម្រិតថ្នាក់ដឹកនាំ ទីប្រឹក្សាថ្នាក់ដឹកនាំ និងគ្រប់គ្រង
- ប្រភេទ ខៈ សម្រាប់កម្រិតប្រតិបត្តិផ្ទាល់

## ខ. ការដាក់ពាក្យស្នើសុំ

- ត្រូវស្នើឡើងដោយកម្មសិទ្ធិករ និង/ឬប្រតិបត្តិករកាស៊ីណូ
- បំពេញពាក្យស្នើសុំ និងត្រូវដាក់ពាក្យនៅអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.**
- អគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** នឹងជូនដំណឹងពីការទទួល ឬបដិសេធពាក្យស្នើសុំក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីទទួលឯកសារពេញលេញ។

## គ. ពិនិត្យអនុម័ត

ពិនិត្យសម្រេចអនុម័តដោយអគ្គលេខាធិការ **គ.ល.ក.** តាមការប្រទានសិទ្ធិរបស់ប្រធាន **គ.ល.ក.**។

## ឃ. សុពលភាព

មិនលើសពី ៣ ឆ្នាំ → បន្តសុពលភាពក្នុងរយៈពេលយ៉ាងតិច ៣ ខែ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
អគ្គលេខាធិការដ្ឋាន

Form-C005

ពាក្យស្នើសុំអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ
Application Form to Apply for Casino Special Employee License

**ផ្នែកទី១៖ គោលបំណងនៃការដាក់ពាក្យ / PURPOSE OF APPLICATION**

- ☐ ស្នើសុំអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ / Apply for Casino Special Employee License
- ☐ ស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ / Apply for Renew Casino Special Employee License
- ☐ ស្នើសុំប្តូរប្រភេទអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ / Apply for Change Casino Special Employee License

**ផ្នែកទី២៖ ព័ត៌មានកាស៊ីណូ និងអ្នកដាក់ពាក្យស្នើសុំ / CASINO AND APPLICANT INFORMATION**

| | | | | |
|---|---|---|---|---|
| នាមករណ៍កាស៊ីណូ Casino name | អក្សរខ្មែរ in Khmer | ............ | អក្សរឡាតាំង in Latin | ............ |
| លេខអាជ្ញាបណ្ណកាស៊ីណូ Casino License Number | ............ | | សុពលភាពអាជ្ញាបណ្ណ License Validity | ............ |
| តួនាទីអ្នកដាក់ពាក្យស្នើសុំ Position of Applicant | ☐ ប្រធានក្រុមប្រឹក្សាភិបាល/ BoD | | ☐ អភិបាល/ Director | ☐ នាយក/ CEO |
| គោត្តនាម និងនាម Last name and First name | អក្សរខ្មែរ in Khmer | ............ | អក្សរឡាតាំង in Latin | ............ |
| ភេទ / Sex | ☐ ប្រុស / Male | | ☐ ស្រី / Female | |
| ថ្ងៃខែឆ្នាំកំណើត / Date of Birth | ............ | | សញ្ជាតិ / Nationality | ............ |
| ☐ អត្តសញ្ញាណប័ណ្ណ/ Identification Card ☐ លិខិតឆ្លងដែន/ Passport | លេខ/ Number ............ | | ថ្ងៃខែឆ្នាំផុតកំណត់ / Expiry Date ............ | |
| អាសយដ្ឋាន / Address | ............ | | | |
| ទូរស័ព្ទចល័ត Mobile Phone Number | ............ | | | |
| សារអេឡិចត្រូនិច Email Address | ............ | | | |

**ផ្នែកទី៣៖ ព័ត៌មានអំពីចំនួនបុគ្គលិកដែលត្រូវស្នើសុំអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ / INFORMATION ON NUMBER OF EMPLOYEES APPLYING FOR CASINO SPECIAL EMPLOYEE LICENSE**

| បរិយាយ / Description | ចំនួនសរុប / Total Number | ខ្មែរ/Cambodians | បរទេស/Foreigners |
|---|---|---|---|
| ចំនួនបុគ្គលិកពិសេសកាស៊ីណូ Number of Casino Special Employees | ............ | ............ | ............ |

១

# ៣. បុគ្គលិកពិសេសកាស៊ីណូ (ត)

## ង. កម្រៃទម្រង់ការនិងអាជ្ញាបណ្ណ

| មុខសញ្ញាចំណាយ | ប្រភេទ ក | ប្រភេទ ខ |
|---|---|---|
| កម្រៃទម្រង់ការ | ▪ ចាប់ពី ១ នាក់ ដល់ ២៥ នាក់ ចំនួន ២០ម៉ឺន រៀល<br>▪ ចាប់ពី ២៥ នាក់ ដល់ ៥០ នាក់ ចំនួន ៤០ម៉ឺន រៀល<br>▪ ចាប់ពី ៥០នាក់ ឡើងទៅ ចំនួន ៦០ម៉ឺន រៀល | |
| កម្រៃអាជ្ញាបណ្ណ៖<br>១. ខ្មែរ<br>២. បរទេស | ២០ម៉ឺន រៀល/នាក់<br>៨០ម៉ឺន រៀល/នាក់ | ១០ម៉ឺន រៀល/នាក់<br>៤០ម៉ឺន រៀល/នាក់ |
| បោះពុម្ពឡើងវិញ ប្តូរប្រភេទអាជ្ញាបណ្ណ | ២០ម៉ឺនរៀល | |

## ច.កាតព្វកិច្ចប្រតិបត្តិករកាស៊ីណូចំពោះបុគ្គលិកពិសេសកាស៊ីណូ

- ត្រូវចេញបណ្ណសម្គាល់ខ្លួនដល់បុគ្គលិកពិសេសកាស៊ីណូទាំង ២ ប្រភេទ និងតម្រូវឱ្យបុគ្គលិកពាក់បណ្ណសម្គាល់ខ្លួនជាប្រចាំក្នុងពេលបំពេញការងារ
- ត្រូវស្នើសុំប្តូរប្រភេទអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ករណីផ្លាស់ប្តូរតួនាទី
- ត្រូវរៀបចំបញ្ជីឈ្មោះបុគ្គលិកកាស៊ីណូសរុប ដោយបញ្ជាក់ពីមុខតំណែង ផ្តល់ជូន **អ.គ.ល.ក.**
- ជូនដំណឹងមក អ.គ.ល.ក. ករណីមានបុគ្គលិកលាឈប់ ឬត្រូវបានបញ្ឈប់ពីការងារ ក្នុងរយៈពេល ៧ថ្ងៃ
- ត្រូវរៀបចំបញ្ជីឈ្មោះបច្ចុប្បន្នភាពបុគ្គលិកពិសេសកាស៊ីណូ (កំពុងបំពេញការងារ, លាឈប់) ប្រចាំឆ្នាំ ជូន **អ.គ.ល.ក.** ត្រឹមថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់
- ត្រូវទទួលខុសត្រូវលើថ្លៃចំណាយពាក់ព័ន្ធនឹងការស្នើសុំអាជ្ញបណ្ណបុគ្គលិកពិសេស និងទោសទណ្ឌដែលបុគ្គលិកពិសេសបានប្រព្រឹត្តក្នុងការបំពេញការងារ។

# ៤. ការចុះបញ្ជីប្រភេទ វិធាន ឧបករណ៍ និង/ឬកម្មវិធីល្បែង

- មាត្រា៧៤ នៃច្បាប់ បានចែងថា "ប្រតិបត្តិករល្បែងពាណិជ្ជកម្ម មិនត្រូវដំណើរការល្បែងណាមួយនៅក្នុងគ្រឹះស្ថានល្បែងពាណិជ្ជកម្ម ឡើយលុះត្រាតែ៖
  - មានការយល់ព្រមជាមុនពី **គ.ល.ក.** ដែលការយល់ព្រមនេះ នៅមានសុពលភាព។
  - ល្បែងនោះ ត្រូវបានដំណើរការ ឬលេងស្របតាមរបៀបលេងនិងវិធានល្បែងដែលអនុម័តដោយ **គ.ល.ក.**
  - ល្បែងនោះត្រូវដំណើរការដោយបុគ្គលិកពិសេសដែលមានអាជ្ញាបណ្ណ។"

**ការចុះបញ្ជីប្រភេទល្បែង**

**ការចុះបញ្ជីវិធានល្បែង**

**ការចុះបញ្ជីឧបករណ៍និង/ឬកម្មវិធីល្បែង**

- **ការដាក់ពាក្យស្នើសុំ៖** បំពេញពាក្យនិងដាក់ពាក្យស្នើសុំនៅអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ដោយភ្ជាប់នូវឯកសារតម្រូវ និងបង់កម្រៃតាមការកំណត់ក្នុងប្រកាសលេខ ០០៩ គ.ល.ក.ប្រក ស្តីពីការគ្រប់គ្រងលើវិធានល្បែង ឧបករណ៍ និង/ឬកម្មវិធីល្បែង សម្រាប់ប្រតិបត្តិការកាស៊ីណូ។

# ៥. ការនាំចូលឧបករណ៍និង/ឬកម្មវិធីល្បែង

*មាត្រា៧៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម*

*ប្រភេទនិងចំនួនឧបករណ៍ ឬ/និងកម្មវិធីល្បែង ដែលត្រូវផលិត ដំឡើង នាំចូល ចែកចាយ រួមទាំង នាំចេញជាថ្មី និងកម្ទេចចោល ត្រូវមានការអនុញ្ញាតពី **គ.ល.ក.** និងត្រូវអនុលោមតាមបញ្ញត្តិនៃច្បាប់នេះ។ **គ.ល.ក.** អាចចេញនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការចុះបញ្ជីលើប្រភេទ ឧបករណ៍ល្បែងមួយចំនួន ដូចជា ស្លត់ម៉ាស៊ីន និងម៉ាស៊ីនល្បែងពាណិជ្ជកម្មដទៃទៀត។ ឧបករណ៍ឬ/និងកម្មវិធីល្បែងដែលត្រូវបានអនុញ្ញាតឱ្យដំណើរការនៅក្នុងកាស៊ីណូ ឬគ្រឹះស្ថានល្បែងពាណិជ្ជកម្មដទៃទៀត ត្រូវមានយថាប្រភេទអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់ដោយ **គ.ល.ក.**។*

- រាល់ឧបករណ៍ និង/ឬកម្មវិធីល្បែង ត្រូវនាំចូលដោយក្រុមហ៊ុនដែលមានអាជ្ញាបណ្ណ ឬមានការទទួលស្គាល់ពី **គ.ល.ក.**។
- ឧបករណ៍ និង/ឬកម្មវិធីល្បែង ដែលអាចនាំចូលបាន គឺមានអាយុកាលមិនលើពី ១០ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការផលិត។
- ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលឧបករណ៍/កម្មវិធីល្បែង ត្រូវធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក តាមប្រព័ន្ធបញ្ចូរតែមួយជាតិ មានគេហទំព័រ www.nsw.gov.kh ដោយភ្ជាប់នូវឯកសារតាមការកំណត់របស់ **អ.គ.ល.ក.**។

# III. ការគ្រប់គ្រងបញ្ជីគណនេយ្យនិងហិរញ្ញវត្ថុ

| ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម | | ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម | |
|---|---|---|---|
| **មាត្រា៥៥** | ត្រូវរៀបចំ និងរក្សាកិច្ចបញ្ជិកាគណនេយ្យអនុលោមតាមបទដ្ឋានគណនេយ្យជាធរមានដែលបង្ហាញអំពីប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុនៃប្រតិបត្តិការល្បែងពាណិជ្ជកម្មរបស់ខ្លួន | **មាត្រា២០** | សហគ្រាសនិងអង្គការមិនស្វែងរកប្រាក់ចំណេញមានកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ។ |
| **មាត្រា៥៦** | ត្រូវជានាឱ្យមានសវនកម្មឯករាជ្យប្រចាំឆ្នាំលើរបាយការណ៍ហិរញ្ញវត្ថុ និងផ្តល់របាយការណ៍សវនកម្មនោះទៅ **គ.ល.ក.** | **មាត្រា២១** | កាលបរិច្ឆេទគណនេយ្យនីមួយៗ ត្រូវកំណត់រយៈពេលចំនួន ១២ ខែ **គិតចាប់ពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំដដែល។** |
| **មាត្រា៥៧** | ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍ និងព័ត៌មានដទៃទៀតប្រចាំគ្រាពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន តាមពេលវេលា និងបែបបទដែលកំណត់ដោយ **គ.ល.ក.** | **មាត្រា២២** | - បញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវធ្វើជាភាសាខ្មែរ និងប្រាក់រៀល។<br>- អាចធ្វើជាភាសាអង់គ្លេស និងជារូបិយបណ្ណបរទេសអមជាមួយបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ជាភាសាខ្មែរ និងប្រាក់រៀល។ |
| | | **មាត្រា២៣** | ត្រូវរក្សាទុករាល់ឯកសារគណនេយ្យ យ៉ាងតិច ១០ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការបង្កើតឯកសារ។ |

# III.ការគ្រប់គ្រងបញ្ជីគណនេយ្យនិងហិរញ្ញវត្ថុ

**តារាងឯកសារគណនេយ្យ និងលិខិតយុត្តិការនានា ដែលប្រតិបត្តិករ និង/ឬ កម្មសិទ្ធករកាស៊ីណូ ត្រូវរៀបចំ និងផ្តល់ជូន អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ឧបសម្ព័ន្ធ១ នៃ លិខិតលេខ ០០១/២៤ អ.គ.ល.ក. ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០២៤**

ឧបសម្ព័ន្ធ១

**តារាងឯកសារគណនេយ្យ និងលិខិតយុត្តិការនានាដែលប្រតិបត្តិករ និង/ឬកម្មសិទ្ធិករ កាស៊ីណូត្រូវរៀបចំ និងផ្តល់ជូនអគ្គលេខាធិការដ្ឋាននៃ គ.ល.ក.**

ឧបសម្ព័ន្ធនៃលិខិតលេខ ០០១/២៤ អ.គ.ល.ក. ចុះថ្ងៃទី ២ ខែ មករា ឆ្នាំ២០២៤

| ល.រ. | ឈ្មោះឯកសារ | ប្រភេទឯកសារ |
|---|---|---|
| **១. ឯកសារសវនកម្មឯករាជ្យប្រចាំឆ្នាំ** | | |
| ១.១ | របាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យរួច (Audited Report) | PDF |
| ១.២ | របាយការណ៍គណៈគ្រប់គ្រង (Management Letter) | PDF |
| ១.៣ | របាយការណ៍កែតម្រូវពីក្រុមហ៊ុនសវនករឯករាជ្យ (Working Adjustments) (ប្រសិនបើមាន) | EXCEL |
| **២. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មុនទទួលរងសវនកម្មឯករាជ្យ (Unaudited Financial Statements)** | | |
| ២.១ | របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (Statement of financial position) | PDF និង EXCEL |
| ២.២ | របាយការណ៍ចំណេញឬខាត និងចំណូលលម្អិតផ្សេងៗ (Statement of profit or loss and others comprehensive income) | PDF និង EXCEL |
| ២.៣ | របាយការណ៍បម្រែបម្រួលមូលធន (Statement of Changes in equity) | PDF និង EXCEL |
| ២.៤ | របាយការណ៍លំហូរសាច់ប្រាក់ (Statement of cash flow) | PDF និង EXCEL |
| **៣. របាយការណ៍សវនកម្មផ្ទៃក្នុង (Internal Audit Report)** | | PDF |
| **៤. បញ្ជីគណនេយ្យ** | | |
| ៤.១ | ទិន្នានុប្បវត្តិ ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ នៃការិយបរិច្ឆេទគណនេយ្យ (General Ledgers) | EXCEL |
| ៤.២ | តារាងតុល្យការសាកល្បង (Trail Balance) | PDF និង EXCEL |
| **៥. ឯកសារប្រតិបត្តិការអាជីវកម្ម** | | |
| ៥.១ | ប័ណ្ណស្នើសុំហ្វិល (Request for fill) និងប័ណ្ណហ្វិល (Fill Slip) | PDF |
| ៥.២ | ប័ណ្ណស្នើសុំក្រេឌីត (Request for credit) និងប័ណ្ណក្រេឌីត (Credit Slip) | PDF |
| ៥.៣ | ឯកសារបញ្ជាក់ពីសារពើភ័ណ្ឌដើមគ្រា (Opening Inventory), សារពើភ័ណ្ឌចុងគ្រា (Closing Inventory), ទម្លាក់ (Drop) | PDF |
| ៥.៤ | រូបថតទិន្នន័យរបស់ម៉ាស៊ីនល្បែងប្រចាំថ្ងៃ គិតចាប់ពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ នៃការិយបរិច្ឆេទគណនេយ្យ (Daily Gaming Machine Accounting /Jurisdictional Meter Photo) | PDF |
| ៥.៥ | តារាងកត់ត្រាទិន្នន័យរបស់ម៉ាស៊ីនល្បែង (Meter Reading) | PDF និង EXCEL |



| | | |
|---|---|---|
| ៥.៦ | ឯកសារបញ្ជាក់ពីទម្លាក់ (Coin In), ការកាត់បន្ថយ (Coin Out) និងការទូទាត់ដោយដៃ (Cancelled Credit, Jackpot, Hand pay, Short pay) សម្រាប់ម៉ាស៊ីនល្បែងប្រចាំថ្ងៃ | PDF |
| ៥.៧ | របាយការណ៍បិទខេចប្រចាំថ្ងៃ (Daily Cage Closing report) | PDF |
| ៥.៨ | ប័ណ្ណហ្វិលកាក់ល្បែង និងប័ណ្ណហ្វិលសាច់ប្រាក់ប្រចាំថ្ងៃពីមែនបែងមកផ្នែកបេឡា (Daily Inventory Chips and Cash Fill from main bank to cashier's cage) | PDF |
| ៥.៩ | ប័ណ្ណក្រេឌីតកាក់ល្បែង និងប័ណ្ណក្រេឌីតសាច់ប្រាក់ប្រចាំថ្ងៃពីផ្នែកបេឡាទៅមែនបែង (Daily Inventory Chips and Cash Credit from cashier's cage to main bank) | PDF |
| ៥.១០ | បញ្ជីប្តូរសាច់ប្រាក់ និងកាក់ល្បែងប្រចាំថ្ងៃ (Daily Cash buy-in and cash out listing) | PDF និង EXCEL |
| ៥.១១ | សន្លឹបគ្រាប់សាច់ប្រាក់ប្រចាំថ្ងៃ, ប្រចាំខែ និងប្រចាំឆ្នាំ របស់តុល្បែង ម៉ាស៊ីនល្បែង ផ្នែកបេឡា មែនបែង ឬទូប្រាក់។ល។ (Cash Count Sheet) | PDF |
| ៥.១២ | បញ្ជីរាយនាមឧបករណ៍ និង/ឬកម្មវិធីល្បែងដែលបានដំណើរការក្នុងឆ្នាំ២០២៣ | PDF |
| ៥.១៣ | តារាងវេនបំពេញការងាររបស់បុគ្គលិកទាំងអស់ | PDF |

***កំណត់សម្គាល់៖*** អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. រក្សាសិទ្ធិក្នុងការកែប្រែបញ្ជីឯកសារតម្រូវតាមការចាំបាច់។

# IV. ការគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់ និងផលប៉ះពាល់ពីល្បែង

រាជរដ្ឋាភិបាលបានគិតគូរយ៉ាងយកចិត្តទុកដាក់ពាក់ព័ន្ធនឹងល្បែងស៊ីសងគ្រប់ប្រភេទ ដោយមិនអនុញ្ញាតឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបលេងល្បែងស៊ីសងនោះទេ។

| **ការរឹតត្បិតពីការលេងល្បែង (មាត្រា៦៨)** | **ការហាមឃាត់ការធ្វើសកម្មភាព (មាត្រា៧២)** |
| --- | --- |
| បុគ្គលមានវិបត្តិស្មារតី អសមត្ថភាពហិរញ្ញវត្ថុ ក្ស័យធន | ប្រតិបត្តិករ អាចហាមឃាត់បុគ្គលណាមួយមិនឱ្យចូលគ្រឹះស្ថានល្បែង (លើកលែងមន្ត្រី **គ.ល.ក.**) |
| ស្ថិតក្រោមឥទ្ធិពលគ្រឿង ស្រវឹង ឬថ្នាំញៀន | សកម្មភាពដែលប៉ះពាល់ដល់សន្តិសុខសណ្តាប់សាធារណៈ |
| យកអាវុធមកជាមួយ | ការលេងល្បែងដោយបន្លំ ឬឆបោក |
| អាយុក្រោម១៨ ឆ្នាំ | សកម្មភាពស្រវឹង ឬកាយវិការឥតសណ្តាប់ធ្នាប់ ឬច្រងេងច្រងាង |
| ប្រជាពលរដ្ឋខ្មែរទូទៅ ដោយរួមទាំងកងកម្លាំងប្រដាប់អាវុធ អ្នករាជការសាធារណៈ និងពលរដ្ឋទទួលអាណត្តិដោយការបោះឆ្នោត ត្រូវបានហាមឃាត់ដាច់ខាតមិនឱ្យចូលលេងល្បែងនៅក្នុងកាស៊ីណូ ឬគ្រឹះស្ថានល្បែងពាណិជ្ជកម្ម។ | ការបំពានលក្ខខណ្ឌនិងបទបញ្ជាផ្ទៃក្នុងរបស់កាស៊ីណូ ឬគ្រឹះស្ថានល្បែងពាណិជ្ជកម្ម |

# IV. ការគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់ និងផលប៉ះពាល់ពីល្បែង

## គំរូស្លាកសញ្ញា






# IV. ការគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់ និងផលប៉ះពាល់ពីល្បែង

ប្រតិបត្តិករកាស៊ីណូ និង/ឬកម្មសិទ្ធិករកាស៊ីណូ ត្រូវគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់ ដូចខាងក្រោម៖

- ➢ ខណ្ឌចែកកន្លែងលេងល្បែងច្បាស់លាស់ និងដាក់ស្លាកសញ្ញាសម្គាល់សមស្រប ដើម្បីបង្ហាញទីតាំងលេងល្បែង
- ➢ ដាក់ស្លាកសញ្ញាហាមឃាត់ ចំពោះបុគ្គលដែលត្រូវបានរឹតត្បិតពីការលេងល្បែង នៅច្រកទ្វារចេញ-ចូលបរិវេណកាស៊ីណូ (ច្បាស់លាស់ ងាយស្រួលក្នុងការមើល អាន និងយល់)
- ➢ បំពាក់កាមេរ៉ាសុវត្ថិភាព (CCTV) គ្រប់គ្រាន់នៅច្រកទ្វារចេញ-ចូល និងក្នុងបរិវេណកាស៊ីណូ ដើម្បីក្តាប់ឱ្យបានរាល់សភាពការណ៍ដែលកើតមានឡើងនៅក្នុងកាស៊ីណូ ហើយកាមេរ៉ាសុវត្ថិភាព (CCTV) ទាំងនោះត្រូវមានអង្គចងចាំអាចរក្សាទុកទិន្នន័យមិនក្រោមរយៈពេល ៦ ខែ ដើម្បីបម្រើឱ្យការងារជំនាញ
- ➢ មានកម្លាំងភ្នាក់ងារសន្តិសុខនិងមានយន្តការតាមដានត្រួតពិនិត្យការចូលលេងល្បែងរបស់ភ្ញៀវល្បែង កំណត់អត្តសញ្ញាណភ្ញៀវល្បែង និងមុខសញ្ញាហាមឃាត់ដែលត្រូវបានរឹតត្បិតដោយច្បាប់
- ➢ រក្សាទុករបាយការណ៍បច្ចុប្បន្នភាពអំពីភ្ញៀវចូលលេងល្បែងក្នុងកាស៊ីណូរបស់ខ្លួន
- ➢ ហាមឃាត់បុគ្គលដែលត្រូវបានរឹតត្បិតពីការចូលលេងល្បែងនៅក្នុងកាស៊ីណូរបស់ខ្លួន និងបណ្តេញបុគ្គលទាំងនោះចេញពីទីតាំងលេងល្បែង

# IV. ការគ្រប់គ្រងសន្តិសុខសណ្ដាប់ធ្នាប់ និងផលប៉ះពាល់ពីល្បែង

- ត្រូវមានបទបញ្ជាផ្ទៃក្នុងតឹងរ៉ឹង និងហាមឃាត់មិនឱ្យលេងល្បែង ក្នុងគ្រឹះស្ថានល្បែងពាណិជ្ជកម្មរបស់ខ្លួនចំពោះកម្មករ បុគ្គលិក និងនយោជិតដែលកំពុងបម្រើការងារ
- ត្រូវអនុវត្តកាតព្វកិច្ចប្រឆាំងសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មតាមរយៈកាស៊ីណូ
- ត្រូវគ្រប់គ្រងសភាពការណ៍ និងផ្ដល់ព័ត៌មានទាន់ពេលវេលា និងជាប់ជាប្រចាំអំពីសកម្មភាពអាជីវកម្ម និងសកម្មភាពល្មើសផ្សេងៗ ដែលកើតមានឡើងនៅក្នុងបរិវេណទីតាំងរបស់ខ្លួន
- ត្រូវចូលរួមសហការនិងទប់ស្កាត់បទល្មើសនានាតាមរយៈកាស៊ីណូ ដូចជា ការបង្ខាំងមនុស្សខុសច្បាប់, ឧក្រិដ្ឋកម្មឆ្លងដែន, ការជួញដូរគ្រឿងញៀន និងការជួញដូរមនុស្ស និងត្រូវរាយការណ៍មក **គ.ល.ក.** និងអាជ្ញាធរមានសមត្ថកិច្ចឱ្យបានទាន់ពេលវេលា
- ត្រូវចងក្រង ធ្វើបច្ចុប្បន្នភាព និងរក្សាទុកនូវឯកសារពាក់ព័ន្ធនឹងការចុះអនុវត្តនីតិវិធីរបស់សមត្ថកិច្ចពាក់-ព័ន្ធ នៅក្នុងទីតាំងរបស់ខ្លួន ហើយត្រូវធ្វើរបាយការណ៍ជាប្រចាំមក **គ.ល.ក.**។

# V. ទោសទណ្ឌ

ករណីមិនអនុវត្តកាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ត្រូវទទួលរងទោសទណ្ឌ ដូចខាងក្រោម៖

## ទណ្ឌកម្មរដ្ឋបាល

- ការព្រមានជាលាយលក្ខណ៍អក្សរ, ការព្យួរ និងការដកហូត
- បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការដាក់ទណ្ឌកម្មរដ្ឋបាល មានកំណត់ក្នុងប្រកាសលេខ ០០៥ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាលនិងពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

## ពិន័យអន្តរការណ៍

- អនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

## ការបង្ក្រាប

- រាល់ប្រតិបត្តិការកាស៊ីណូដែលមិនមានអាជ្ញាបណ្ណកាស៊ីណូ ពី **គ.ល.ក.** ត្រូវចាត់ទុកថាជាការធ្វើអាជីវកម្មល្បែងស៊ីសងខុសច្បាប់ នឹងត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

## គេហទំព័រផ្លូវការ

www.cgmc.gov.kh

Website

## ទំព័រហ្វេសប៊ុកផ្លូវការ

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការ
គ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

Facebook

# សូមអរគុណ